# សេចក្តីថ្លែងការណ៍រួម៖ អង្គការសង្គមស៊ីវិលអំពាវនាវឱ្យអាជ្ញាធរកម្ពុជាបង្កើនការប្រយុទ្ធប្រឆាំងនិទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន

ភ្នំពេញ ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ ២០២១ —— នៅក្នុងទិវាអន្តរជាតិបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាននេះ យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោម សម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះបរាជ័យរបស់រដ្ឋាភិបាលកម្ពុជាក្នុងការចាប់អ្នកប្រព្រឹត្តបទល្មើសនៃឧក្រិដ្ឋកម្មដែលបានប្រព្រិត្តលើអ្នកសារព័ត៌មាននៅក្នុងប្រទេសកម្ពុជាមកផ្តន្ទាទោស។ យើងខ្ញុំសូមទទូចឱ្យអាជ្ញាធរកម្ពុជាចាត់វិធានការជាបន្ទាន់ដើម្បីធានាឱ្យមានការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យភាព និងតម្លាភាពទៅលើគ្រប់ករណីបទល្មើសទាំងអស់ដែលបានកើតឡើង និងយុត្តិធម៌ត្រូវបានផ្តល់ជូនដល់ជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ។

ចាប់តាំងពីឆ្នាំ ១៩៩៤មក យ៉ាងតិចណាស់មានអ្នកសារព័ត៌មានចំនួន **១៧នាក់** ត្រូវបានសម្លាប់និងស្លាប់នៅកម្ពុជា។ ករណីស្ទើរតែទាំងអស់ ជនរងគ្រោះត្រូវបានសម្លាប់ដោយសារតែការងាររបស់ពួកគេ។ ជាក់ស្តែងការស្លាប់របស់ជនរងគ្រោះចំនួន ១២នាក់ក្នុងចំណោម ១៧នាក់ខាងលើគឺពួកគេត្រូវបានសម្លាប់ក្នុងខណៈពួកគេបានធ្វើការរាយការណ៍ព័ត៌មានអំពីបញ្ហារសើប។ ក្នុងចំណោមករណីទាំង១៧ មាន១២ករណីដែលអ្នកប្រព្រឹត្តបទល្មើសមិនត្រូវបាននាំយកមកផ្តន្ទាទោសពីបទឃាតកម្មលើអ្នកសារព័ត៌មានទាំងអស់នោះទេ។

ឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាននិងការធ្វើទុក្ខបុកម្នេញលើអ្នកសារព័ត៌មានហាក់នៅតែកើតឡើងជាបន្តបន្ទាប់គួរឱ្យព្រួយបារម្ភ។ ក្នុងរយៈពេល ១០ខែចុងក្រោយនេះ (ចាប់ពីខែមករា ដល់ខែតុលា ឆ្នាំ២០២១) ខេមបូចារកឃើញថាមានអ្នកសារព័ត៌មានសរុប ៨១នាក់ បានទទួលរងនូវការធ្វើទុក្ខបុកម្នេញក្នុងរូបភាពផ្សេងៗ។ ក្នុងនោះមានអ្នកសារព័ត៌មានចំនួន ៣១នាក់ (ស្រ្តី៤នាក់) ត្រូវបានចាប់ខ្លួន ២០នាក់ទទួលរងការប្រើអំពើរហិង្សា ១៦នាក់ទទួលរងការគំរាមកំហែង ៨នាក់ទទួលរងពាក្យបណ្តឹងពីតុលាការ ៥នាក់ទទួលរងការឃាត់ខ្លួនដើម្បីសួរចម្លើយ និងអ្នកសារព័ត៌មានស្រ្តី១នាក់ទទួលរងការបៀតបៀនផ្លូវភេទ។

ឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកសារព័ត៌មានមានលក្ខណៈធ្ងន់ធ្ងរ និងជាការគំរាមកំហែងយ៉ាងពិតប្រាកដ ហើយមិនត្រឹមតែចំពោះអ្នកសារព័ត៌មានប៉ុណ្ណោះទេ។ អ្នកសារព័ត៌មានមានបេសកកម្មយ៉ាងសំខាន់ក្នុងការរាយការណ៍ហេតុការណ៍ដែលបានកើតឡើង សរសេរបទវិភាគ និងបទអត្ថាធិប្បាយ ដើម្បីគាំទ្រឱ្យមានការបញ្ចេញមតិ និងជជែកពិភាក្សាយ៉ាងរស់រវើក។ អ្នកសារព័ត៌មានឯករាជ្យ ដើរតួយ៉ាងសំខាន់ក្នុងការទាមទារឱ្យអ្នកមានអំណាចមានទំនួលខុសត្រូវ និងរួមចំណែកយ៉ាងសំខាន់ទៅក្នុងសង្គមដែលមានយុត្តិធម៌។

នៅពេលដែលអ្នកសារព័ត៌មានគឺជាមុខសញ្ញានៃអំពើហិង្សា ដោយសារតែអ្វីដែលគេបានសរសេរ ឬបានរាយការណ៍ នោះសេរីភាពបញ្ចេញមតិត្រូវបានរារាំង ហើយជំនួសដោយការរឹតត្បិតសេរីភាពខ្លួនឯងនិងការភ័យខ្លាច ដែលធ្វើឱ្យសាធារណជននឹងពុំមានព័ត៌មាន ហើយអ្នកមានអំណាចនឹងមិនត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួននោះទេ។ លើសពីនេះ នៅពេលរដ្ឋាភិបាលខកខានក្នុងការស៊ើបអង្កេតយ៉ាងត្រឹមត្រូវ និងដាក់ទណ្ឌកម្មចំពោះអំពើហិង្សាលើអ្នកសារព័ត៌មាន នេះជាសារបង្ហាញថាឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មានគឺត្រូវបានអនុញ្ញាត។

យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោម សូមថ្កោលទោសចំពោះនិទណ្ឌភាពដែលឧក្រិដ្ឋកម្មប្រព្រឹត្តលើអ្នកសារព័ត៌មានត្រូវបានកើតមាននៅក្នុងប្រទេសកម្ពុជា ដែលធ្វើឱ្យប៉ះពាល់ដល់សង្គមកម្ពុជាទាំងមូល។ យើងខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាឱ្យចាត់វិធានការជាក់ស្ដែង ដើម្បីធានាថាការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យ និងតម្លាភាព ចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនេះត្រូវបានធ្វើឡើងហើយជនល្មើសត្រូវបាននាំមកផ្ដន្ទាទោស។ យើងក៏សូមឱ្យរាជរដ្ឋាភិបាលចាត់វិធានការជាបន្ទាន់ ដើម្បីធានាសុវត្ថិភាព និងសន្តិសុខដល់អ្នកសារព័ត៌មានគ្រប់រូប ដើម្បីឱ្យពួកគេអាចអនុវត្តសិទ្ធិសេរីភាព ចូលរួមរាយការណ៍ព័ត៌មាននានាដែលកំពុងកើតមានឡើងនៅក្នុងសង្គមដោយមិនមានភាពភ័យខ្លាច៕

សេចក្ដីថ្លែងការណ៍នេះគាំទ្រដោយ៖

១. អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)

២. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)

៣. សមគមកម្ពុជាដើម្បីការពារអ្នកកាសែត (CAPJ)

៤. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

៥. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)

៦. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)

៧. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)

៨. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា (COMFREL)

៩. សហព័ន្ធអ្នកសារព័ត៌អន្តរជាតិ (IFJ)